# ប្រអប់ ព្រួយបារម្ភ

ដោយ អូលីវីយ៉ា យីធីមែន
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅក្នុង ស.រ.អា. ។*

អូលីវីយ៉ា បានប្រញាប់ចេញពីថ្នាក់រៀនរបស់នាងមុនពេលរៀនចប់ ។ នាងបានព្យាយាមមិនមើលមុខនរណាម្នាក់ចំភ្នែកនោះទេ ។

ថ្ងៃនេះគឺជាថ្ងៃដំបូងនៃការព្យាបាលរបស់ អូលីវីយ៉ា ។ ម្ដាយរបស់នាងបានពន្យល់ថានាងនឹងជួបជាមួយគ្រូពេទ្យដែលអាចជួយនាងព្យាបាលការព្រួយបារម្ភរបស់នាងបាន ។ អូលីវីយ៉ា មានអារម្មណ៍ព្រួយបារម្ភច្រើន ។ ពេលខ្លះនាងមានអារម្មណ៍ព្រួយបារម្ភយ៉ាងខ្លាំង រហូតដល់គេងមិនលក់ ឬពិបាកនឹងរីករាយជាមួយមិត្តភក្តិរបស់នាង ។

អូលីវីយ៉ា បានចូលក្នុងឡានជាមួយម្ដាយ ហើយគេងលក់នៅលើកៅអីរបស់នាង ។

« តើមានរឿងអ្វី ? » ម៉ាក់បានសួរ ។

អូលីវីយ៉ា មិនបានឆ្លើយមួយសន្ទុះ ។ « ហេតុអ្វីកូនត្រូវទៅពេទ្យ ? »

ម៉ាក់ចាប់ផ្ដើមបើកបរ ។ « ព្រះវរបិតាសួគ៌ប្រទានគ្រូពេទ្យដល់យើង ដើម្បីជួយយើង ។ គឺដូចជារបៀបដែលទ្រង់ប្រទានឲ្យយើងនូវអ្វីៗផ្សេងទៀតដើម្បីជួយយើង ដូចជាមិត្តភក្តិ និងព្រះគម្ពីរជាដើម ។ តើកូនចាំពីច្រវាក់ព្រះគម្ពីរដែលយើងបានធ្វើដែរឬទេ ? »

អូលីវីយ៉ា បានងក់ក្បាល ។ ម៉ាក់បានជួយនាងឲ្យរកឃើញខគម្ពីរដែលបានជួយដល់ការព្រួយបារម្ភរបស់នាង ។ នៅក្នុងខគម្ពីរនីមួយៗ ម៉ាក់បានសរសេរពីកន្លែងដែលត្រូវស្វែងរកខគម្ពីរបន្ទាប់ ។ ពេលអូលីវីយ៉ា មានការព្រួយបារម្ភនៅពេលយប់ នាងនឹងពោលពាក្យអធិស្ឋាន ហើយស្វែងរកខគម្ពីរមួយក្នុងចំណោមខគម្ពីរទាំងនោះ ។ បន្ទាប់មក នាងបានអានខគម្ពីរផ្សេងទៀតនៅក្នុងច្រវាក់រហូតដល់នាងងងុយគេង ។

ពេល អូលីវីយ៉ា និងម៉ាក់បានដើរចូលទៅក្នុងការិយាល័យវេជ្ជបណ្ឌិត វេជ្ជបណ្ឌិត ប៉ូស៊ី បានណែនាំខ្លួន ។ គាត់បានសួរអូលីវីយ៉ា អំពីអារម្មណ៍របស់នាង ។ អូលីវីយ៉ា បានប្រាប់គាត់បន្តិចអំពីការព្រួយបារម្ភរបស់នាង ។

« មនុស្សជាច្រើនមានអ្វីមួយហៅថាការថប់បារម្ភ » វេជ្ជបណ្ឌិត ប៉ូស៊ី បាននិយាយ ។ « ពួកគេមានការព្រួយបារម្ភច្រើនដូចប្អូន ប៉ុន្តែប្អូនអាចធ្វើកិច្ចការមួយចំនួនដើម្បីជួយប្អូនឲ្យមានអារម្មណ៍មិនសូវព្រួយបារម្ភ ។ តើប្អូនអាចសាកល្បងមួយក្នុងចំណោមការសាកល្បងនេះជាមួយខ្ញុំបានទេ ? »

អូលីវីយ៉ា បានសម្លឹងមើលស្បែកជើងរបស់នាងហើយងក់ក្បាល ។



*អូលីវីយ៉ា បានគិតច្រើនអំពីការព្រួយបារម្ភរបស់នាង ។*



វេជ្ជ. ប៉ូស៊ី ហុចប្រអប់តូចមួយដល់អូលីវីយ៉ា ។ « នេះជាប្រអប់ព្រួយបារម្ភ វារក្សាការព្រួយបារម្ភរបស់យើងឲ្យមានសុវត្ថិភាព ដូច្នេះយើងមិនចាំបាច់គិតពីរឿងទាំងនោះទេ » ។

អូលីវីយ៉ា បង្វិលប្រអប់មើលនៅក្នុងដៃរបស់នាង ។ វាមើលទៅមិនដូចជាអ្វីពិសេសនោះទេ ។

វេជ្ជបណ្ឌិតបាននិយាយថា ៖ « ពេលក្រោយនៅពេលប្អូនមានអារម្មណ៍ភ័យខ្លាច សូមសរសេរការព្រួយបារម្ភរបស់ប្អូននៅលើក្រដាសមួយសន្លឹកហើយដាក់ក្នុងប្រអប់នេះ » វេជ្ជបណ្ឌិត ប៉ូស៊ី បាននិយាយ ។ « រួចរើសយកពេលមួយដើម្បីបើកប្រអប់ជារៀងរាល់ថ្ងៃសម្រាប់ពេលវេលាព្រួយបារម្ភ ។ បើប្អូនព្រួយបារម្ភអំពីអ្វីមួយមុនពេលនោះមកដល់ សូមនិយាយថា ‹ ខ្ញុំមិនចាំបាច់គិតអំពីរឿងនេះនៅពេលនេះទេ ›»។

អូលីវីយ៉ាបានឆ្លើយ « យល់ព្រម » ។ វេជ្ជ. ប៉ូស៊ី បានជួយនាងឲ្យសរសេរការព្រួយបារម្ភដ៏ធំបំផុតរបស់នាង ហើយអូលីវីយ៉ាបានដាក់វាចូលទៅក្នុងប្រអប់ ។

ក្រោយមក នៅថ្ងៃនោះការព្រួយបារម្ភមួយរបស់អូលីវីយ៉ាបានលេចឡើងនៅក្នុងគំនិតរបស់នាង ។ នាងបានប្រាប់ខ្លួនឯងថា *វាស្ថិតនៅក្នុងប្រអប់ព្រួយបារម្ភ ខ្ញុំអាចព្រួយបារម្ភអំពីរឿងនោះនៅពេលក្រោយ ។* នាងបានព្យាយាមឈប់គិតអំពីរឿងនេះ ។ នាងលេងជាមួយបងប្រុសរបស់នាងជំនួសវិញ ។

លុះពេលចូលគេង អូលីវីយ៉ា មានអារម្មណ៍ភ័យខ្លាច ។ ពេលយប់គឺនៅពេលដែលការព្រួយបារម្ភរបស់នាងបានកើនឡើងយ៉ាងអាក្រក់បំផុត ។ នាងបានដាក់ប្រអប់ព្រួយបារម្ភរបស់នាង និងព្រះគម្ពីររបស់នាងនៅជិតគ្រែរបស់នាង ហើយបានស្រែកហៅម៉ាក់ ។

នាងសួរថា ៖ « ចុះបើគ្មានប្រសិទ្ធភាពវិញនេះ ? »

ម៉ាក់បានឱបនាងយ៉ាងណែន « អីចឹងយើងនៅតែព្យាយាម ព្រះវរបិតាសួគ៌នឹងជួយកូនរកវិធីផ្សេងទៀតដែលជួយបាន »។

អូលីវីយ៉ា បានងក់ក្បាល « ប្រហែលខ្ញុំគួរសរសេរពីរឿងទាំងនោះដាក់ក្នុងប្រអប់ព្រួយបារម្ភផងដែរ » ។

ម៉ាក់បានតបថា « គំនិតល្អណាស់ » ។ គាត់បានពោលពាក្យអធិស្ឋានជាមួយ អូលីវីយ៉ា ។ វាបានធ្វើឲ្យអូលីវីយ៉ាមានអារម្មណ៍ធូរចិត្តបន្តិច ។

បន្តិចក្រោយមក បន្ទាប់ពីម៉ាក់បានបិទភ្លើងហើយ នោះមានការព្រួយបារម្ភមួយបានលេចឡើងក្នុងគំនិតរបស់អូលីវីយ៉ា ។ នាងបានបើកចង្កៀងរបស់នាង ។ នាងបានសរសេរការព្រួយបារម្ភ ហើយដាក់វានៅក្នុងប្រអប់នៅពេលក្រោយ។ នាងបានពោលពាក្យអធិស្ឋានមួយទៀតដើម្បីសុំឲ្យព្រះវរបិតាសួគ៌លួងលោមនាង ។

ក្រោយមកទៀត នាងបានបើកព្រះគម្ពីររបស់នាង ហើយស្វែងរកខគម្ពីរដែលបានគូសចំណាំមកពីច្រវាក់ខគម្ពីររបស់នាង ។ ខគម្ពីរទីមួយដែលនាងបានរកឃើញគឺ អេសាយ ៤១:១០ ។ វាបាននិយាយថា « កុំឲ្យភ័យខ្លាចឡើយ ដ្បិតយើងនៅជាមួយនឹងឯង » ។

នៅជាប់នឹងខគម្ពីរនេះម៉ាក់បានសរសេរថា « គោលលទ្ធិ និងសេចក្ដីសញ្ញា ៦:៣៦ » ។ អូលីវីយ៉ា បានស្វែងរកខគម្ពីរនោះ ហើយអានវាឮៗ ។ « ចូរមើលមកឯយើងដោយនូវគ្រប់ទាំងគំនិត ចូរកុំសង្ស័យ ចូរកុំខ្លាចឡើយ » ។

អូលីវីយ៉ា មានអារម្មណ៍សុខសាន្ត ។ នាងបានដឹងថា នាងប្រហែលជាគិតពីការព្រួយបារម្ភថែមទៀត ។ ប៉ុន្តែព្រះវរបិតាសួគ៌បានប្រទាននូវអ្វីៗជាច្រើនដល់នាង ដើម្បីជួយនាងឲ្យមានអារម្មណ៍កាន់តែប្រសើរឡើង ។ ទ្រង់បានឆ្លើយតបការអធិស្ឋានរបស់នាង ។ ហើយវាបានជួយច្រើនណាស់ ! ●



